# ដំណាំឪឡឹក និង ល្ពៅ

## ការរៀបចំដី និង ការលើករង




ការភ្ជួររាស់ដី | វាស់វែងទីតាំងរង ទៅតាមប្រភេទដំណាំបានណែនាំ | លើករង | ការដាក់ជីសរីរាង្គ (ជីលាមកសត្វ ) ទ្រាប់បាត | កំពស់រង ដែលគ្របប្លាស្ទិចគ្របដី



ការគ្របរង ដោយប្រើចំបើង ឬ ប្លាស្ទិចគ្របដី | ជ្រៀកឫស្សីដើម្បីខ្ទាស់ប្លាស្ទិចគ្របដី ឱ្យជាប់ជាយរង | ខ្ទាស់ជម្រៀកឫស្សី នៅក្បាលរង គែមរង ហើយលាតជុំប្លាស្ទិចគ្របដី តាមបណ្ដោយរង

ទាញប្លាស្ទិចគ្របដី គ្របពីលើរង។ ទាញ បន្តឹងជាយសងខាង ឱ្យតឹងល្មម កុំឱ្យផ្ទៃ ប្លាស្ទិច ធូរ។



រងគ្របប្លាស្ទិចគ្របដី ក្រាលមិនបានត្រឹមត្រូវ (រូបខ្វែង) និង ក្រាលបានត្រឹមត្រូវ (រូបស្ដាំ)





កំណត់ទីតាំងចោះរណ្ដៅសំរាប់ដាំដំណាំ
ចំងាយពីរណ្ដៅមួយ ទៅរណ្ដៅមួយទៀត គឺអាស្រ័យតាមមុខដំណាំ





ចោះរណ្ដៅដោយប្រើកំប៉ុងក្ដៅ (ដាក់ធ្យូងក្នុងកំប៉ុង)។ កំប៉ុងត្រូវចោះរន្ធជុំវិញ គែមខាងលើៗ ដើម្បីឱ្យខ្យល់ចេញចូល ឆេះបានល្អ






ប្លង់រងគំរូ សម្រាប់ដំណាំឪឡឹក




ប្លង់រងគំរូ សម្រាប់ដំណាំល្ពៅ

*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប* (TSTD - TA 7305-CAM)

EAST-WEST SEED INTERNATIONAL

## ការគ្រប់គ្រងគ្រាប់ និង ការថែទាំកូនដំណាំ



លីងល្បាយដី (ដីស្រទាប់លើ ដីសរីរាង្គ និងផេះអង្កាម) បណ្តុះកូនឱ្យបានក្តៅ

ផេះអង្កាម ៦ ភាគ ដីស្រទាប់លើ ២ ភាគ និង ដីកំប៉ុស្តិ៍១ ភាគ លាយច្របល់ចូលគ្នាឱ្យបានសព្វល្អ

ផ្អាប់គ្រាប់ ដោយយកគ្រាប់ទៅពង្រាយក្នុងក្រណាត់ជក់សើមទឹក រួចផ្អាប់គ្រាប់ ដោយទុករយៈពេល ពី ១ ទៅ ២ថ្ងៃ

ដាក់ចំនួន ១ គ្រាប់ក្នុង ១ រន្ធថាសបណ្តុះ




ក្រោយពេលបណ្តុះរួចត្រូវស្រោចទឹក បន្ទាប់មកយកថាសបណ្តុះ ដាក់ក្នុងរោងបណ្តុះ។

រោងបណ្តុះត្រូវមានសំណាញ់កាត់បន្ថយពន្លឺព្រះអាទិត្យ ការពារកុំឱ្យសត្វពាហនៈចូល ហើយមានសំណាញ់ការពារសត្វល្អិតបំផ្លាញកូនដំណាំ

កូនឪឡឹកអាចដាំបាន ចាប់ពីមានអាយុ ពី ៨ ទៅ ១០ ថ្ងៃ ។
មុននឹងដាំ គេត្រូវពង្រឹងកូនឪឡឹក ដោយដាក់វាឱ្យត្រូវពន្លឺថ្ងៃ រយៈពេល ពី ៣ ទៅ៥ ថ្ងៃមុនពេលដាំ។

## ការដាំកូនដំណាំ



យកម្រាមដៃរុញបាតថាសបណ្តុះឡើងលើ ហើយដៃម្ខាងទៀតដកយកកូនដោយថ្នមៗ ដើម្បីកុំឱ្យដាច់ឬសកូន។

សង្កត់ដីថ្នមៗជុំវិញគល់កូនដំណាំ ដើម្បីកុំឱ្យកូនដួល ។ ត្រូវដាំកូន នៅពេលល្ងាច។

ត្រូវគ្របដី ឬ ចំបើង ដើម្បីកាត់បន្ថយកំដៅ។

## ការកាត់តែងមែក (ឪឡឹក)




កាត់(ក្រៀវ)ត្រួយដើមមេ នៅស្លឹក (ថ្នាំង) ទី ៥

កាត់ត្រួយកូនឪឡឹក នៅពេលវាមានស្លឹកទី ៤ ឬ ៥។
តែចំពោះដំណាំល្ពៅ វិញ គេមិនត្រូវកាត់ (ក្រៀវ) ត្រួយវាទេ។

## ការពត់ ឬ តម្រង់ត្រួយ



ពត់ត្រួយឪឡឹក ឱ្យដើមឪឡឹក វារទៅរកចំកណ្តាលចន្លោះរង។ ធ្វើដូច្នេះដើម្បីងាយស្រួលក្នុងការគ្រប់គ្រងដំណាំ ដូចជា មិនដើរជាន់ខ្នែងឪឡឹក នៅពេលដើរស្រោចទឹក។

NIRAS
រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD - TA 7305-CAM)
EAST-WEST SEED INTERNATIONAL

# ការដាក់ ជី



ជីទ្រាប់បាតៈ ត្រូវដាក់ជីសមាស ៥ក្រាម ក្នុងមួយរណ្ដៅ ។ ត្រូវដាក់មុនដាំ រយៈពេល ពី៥ ទៅ ៧ថ្ងៃ ក្នុងជម្រៅ១០ សម (១តឹក) រួចគ្របដីពីលើ ហើយស្រោចទឹក រៀងរាល់ថ្ងៃ រហូតដល់ពេលដាំកូន។




ប្រើឈើ ឬ ឫស្សី ចោះរណ្ដៅដាក់ជីបំប៉ន

ជីបំប៉ន ដាក់ចម្ងាយ ១០ សម ពីគល់ (ពេលអាយុបាន ពី៧ ទៅ២១ថ្ងៃ ក្រោយពីដាំ) និងនៅចម្ងាយ ២០ សម ពេលបានអាយុលើស ពី ២១ថ្ងៃ (ដាក់ជីរួច ត្រូវគ្របដីឱ្យជិតរណ្ដៅជី ដើម្បីការពារការលាកស្លឹក)។




# សត្វល្អិតចង្រៃ និង ជម្ងឺ

   

| ដង្កូវកាត់ស្លឹក | ដង្កូវមូលស្លឹក | ចៃ | រុយស |
|---|---|---|---|
| CUTWORM | LEAFFOLDER | APHID | WHITEFLY |

 





| អណ្ដើកមាស | ដង្កូវស៊ីញៀ | ជម្ងឺទុំលឿងស្លឹក | ជម្ងឺអុចស្លឹក |
|---|---|---|---|
| SQUASH BEETLE | LEAFMINER | DOWNY MILDEW | CERCOSPORA LEAF SPOT |

     

| ជម្ងឺចេញជ័រ | ជម្ងឺរលួយផ្លែ | ជម្ងឺរួញស្លឹកល្ពៅ | ជម្ងឺវីរុសរួញស្លឹកប្រាក់ | ជម្ងឺម៉ូសាអ៊ិកស្លឹកលឿង | ជម្ងឺអុចស្លឹករាងរង្វង់ |
|---|---|---|---|---|---|
| GUMMY STEM BLIGHT | FRUIT ROT | SQUASH LEAF CURL VIRUS | WATERMELON SILVER MOTTLE VIRUS | ZUCCHINI YELLOW MOSAIC VIRUS | PAPAYA RINGSPOT |

# ការប្រមូលផល



Source: http://beselfsufficient.net/6-quick-tips-for-growing-watermelon-from-seeds/

    

NIRAS

រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD - TA 7305-CAM)

EAST-WEST SEED INTERNATIONAL